

# ជំនួយហិរញ្ញវត្ថុដោះស្រាយវិបត្តិ បណ្តាលមកពីព្យុះស៊ីក្លូន Gabrielle

យើងខ្ញុំអាចផ្តល់ជំនួយហិរញ្ញវត្ថុ និងជំនួយផ្សេងៗទៀត ប្រសិនបើអ្នកជាជនរងគ្រោះបណ្តាលពីព្យុះស៊ីក្លូន Gabrielle ។ យើងខ្ញុំមានវិធីផ្សេងៗជាច្រើនដើម្បីជួយអ្នក ហើយយើងខ្ញុំក៏អាចជួយចង្អុលបង្ហាញផ្លូវអ្នក ក្នុងការស្វែងរកជំនួយ ផ្អែកលើស្ថានភាពរបស់អ្នក ។

## ប្រាក់ជំនួយកិច្ចការពារជនស៊ីវិល

ប្រាក់ជំនួយកិច្ចការពារជនស៊ីវិល នឹងមានផ្តល់ជូន ប្រសិនបើអ្នករងផលប៉ះពាល់ពីព្យុះស៊ីក្លូន នៅក្នុងតំបន់ណាមួយខាងក្រោម

- តំបន់ Tairāwhiti
- តំបន់ឆ្នេរសមុទ្រខាងកើត (East Coast region)
- តំបន់ Hawke's Bay (Hawke's Bay region)
- តំបន់ Manawatu (Manawatu region)
- តំបន់ Wairarapa (Wairarapa region)
- តំបន់ Horowhenua (Horowhenua region)
- តំបន់ខាងជើង (Northland region)
- តំបន់ អូកឡិន (Auckland region)
- ក្រុមប្រឹក្សាតំបន់ Waikato
- ក្រុមប្រឹក្សាតំបន់ Thames/Coromandel
- ក្រុមប្រឹក្សាតំបន់ Hauraki
- ក្រុមប្រឹក្សាតំបន់ Matamata/Piako

អ្នកមិនចាំបាច់ ជាពលរដ្ឋដែលទទួលបានជំនួយពីកម្មវិធីរបស់រដ្ឋាភិបាលឡើយ ដើម្បីទទួលបានជំនួយកិច្ចការពារជនស៊ីវិល (Civil Defence Payment) ហើយអ្នកដែលមិនមែនជាពលរដ្ឋរបស់តំបន់ទាំងនោះ ក៏អាចមានសិទ្ធិទទួលបានជំនួយនេះផងដែរ ។ ក្នុងករណីភាគច្រើន អាជ្ញាធរមិនគិតអំពីប្រាក់ចំណូល ឬធនធានដែលអ្នកមានឡើយ ដើម្បីទទួលបានជំនួយនេះ ។

### យើងខ្ញុំអាចជួយអ្នកផ្នែក

- ជំនួយអាហារក្នុងគ្រាអាសន្ន សម្លៀកបំពាក់ និងទីកន្លែងសម្រាក បើផ្ទះសម្បែងរបស់អ្នករងការបំផ្លិចបំផ្លាញ ឬរងការខូចខាត
- បាត់បង់ប្រាក់ចំណូល ដោយសារតែគ្មានលទ្ធភាពធ្វើការ បណ្តាលពីព្យុះស៊ីក្លូន Gabrielle
- ថ្លៃចំណាយផ្សេងៗ បើអ្នកចាំបាច់ត្រូវចាកចេញពីផ្ទះ
- បើកការចំណាយជូន បើមានជនរងគ្រោះស្នាក់នៅជាមួយអ្នក ដូចជានៅក្នុងផ្ទះរបស់អ្នក កន្លែងជួបជុំ (marae) ឬនៅក្នុងមជ្ឈមណ្ឌលសហគមន៍ ។

### អ្នកត្រូវស្ថិតក្នុងស្ថានភាពណាមួយខាងក្រោម បណ្តាលពីស្ថានភាពអាសន្ន

- អ្នកត្រូវចាកចេញពីផ្ទះ (ដូចជា អាជ្ញាធរជម្លៀសអ្នកចេញ ឬស្ថិតក្នុងស្ថានភាពរង់ចាំការជម្លៀសចេញ)
- ក្នុងពេលដែលស្ថានភាពអាសន្នបានកើតឡើង អ្នកបាននៅឆ្ងាយពីផ្ទះ ហើយពេលនេះអ្នកមិនអាចត្រឡប់ទៅផ្ទះ បានឡើយ
- អ្នកត្រូវការជំនួយអាហារ កន្លែងសម្រាក ឬសម្លៀកបំពាក់
- អ្នកមិនអាចទៅធ្វើការបាន ។

### ក្នុងនេះផងដែរ គឺអ្នក

- ប្រាក់ទទួលបានពីការធានារ៉ាប់រង មិនគ្រប់សម្រាប់ការចំណាយ (ឬមិនទាន់ទទួលបានប្រាក់ពីការធានារ៉ាប់រង)
- មិនអាចទទួលបានជំនួយផ្សេងៗ ដូចជា អំណោយសាធារណ: និងមូលនិធិសង្គ្រោះ

បើអ្នកមិនអាចដឹងប្រាកដទេថា ក្រុមហ៊ុនធានារ៉ាប់រងអាចជួយចេញការចំណាយរបស់អ្នកទេនោះ ក៏អ្នកនៅតែមានលក្ខណ:សម្បត្តិទទួលបានជំនួយពី ជំនួយកិច្ចការពារជនស៊ីវិល ដែរ (Civil Defence Payment) ។ ទោះជាយ៉ាងណាក៏ដោយ បើអ្នកទទួលបានជំនួយកិច្ចការពារជនស៊ីវិល (Civil Defence Payment) ហើយក្រោយមកទទួលបានប្រាក់ពីក្រុមហ៊ុនធានារ៉ាប់រង សម្រាប់ការចំណាយណាមួយពីជំនួយនេះ គឺអ្នកត្រូវសងប្រាក់ជំនួយនេះត្រឡប់មកយើងខ្ញុំវិញ ។

សូមស្វែងយល់អំពីអ្វីដែលអ្នកត្រូវប្រាប់យើងខ្ញុំ
**ក្នុងទំព័របន្ទាប់**

**ពេលអ្នកដាក់ពាក្យសុំជំនួយ សូមប្រាប់យើងខ្ញុំអំពី**

- → ឈ្មោះពេញ
- → ថ្ងៃខែឆ្នាំកំណើត
- → លេខទូរស័ព្ទ
- → អាសយដ្ឋានផ្ទះមុនពេលកើតហេតុ
- → អាសយដ្ឋានបច្ចុប្បន្ន (បើអ្នកត្រូវចាកចេញពីផ្ទះ) ។

បើអ្នកដាក់ពាក្យសុំជំនួយ ដោយសារតែអ្នកបាត់បង់ប្រាក់ចំណូល ដោយសារស្ថានភាពអាសន្ន អ្នកក៏ត្រូវប្រាប់យើងខ្ញុំអំពី

- លេខ IRD
- លេខគណនី
- ព័ត៌មានលំអិតអំពីប្រាក់ចំណូលដែលអ្នកបានបាត់បង់រហូតដល់ពេលនេះ
- ព័ត៌មាននិយោជក ដូចជា
  - → ឈ្មោះ
  - → អាសយដ្ឋាន
  - → ឈ្មោះ និង អាសយដ្ឋានរបស់បុគ្គលសម្រាប់ទំនាក់ទំនង

ដើម្បីដាក់ពាក្យសុំជំនួយកិច្ចការពារជនស៊ីវិល (Civil Defence Payment) សូមហៅទូរស័ព្ទមកកាន់ផ្នែកការងារ និងប្រាក់ចំណូល តាមលេខ **0800 400 100** ។

## ជំនួយផ្សេងទៀត

មានវិធីជាច្រើន ដែលក្រុម ការងារ និងប្រាក់ចំណូល (Work and Income) អាចជួយផ្នែកជំនួយបន្ទាន់ និងថ្លៃចំណាយចាំបាច់នានា បើអ្នកកំពុងតែទទួលបានជំនួយពីរដ្ឋាភិបាល ឬជាអ្នកមានប្រាក់ចំណូលទាប ។

Work and Income ក៏ផ្តល់ការជួយផ្សេងទៀតដែរ ដូចជា ស្វែងរកការងារ និងជួយចេញថ្លៃចំណាយផ្ទះសម្បែងរបស់អ្នកផងដែរ ។

ស្ថានភាពរបស់មនុស្សម្នាក់ៗ មានភាពខុសគ្នា ដូច្នេះជំនួយអ្វីដែលអ្នកអាចទទួលបាន ហើយត្រូវបង់ប្រាក់សងយើងខ្ញុំវិញ ឬមិនបាច់ គឺអាស្រ័យលើស្ថានភាពរបស់អ្នក ។

សម្រាប់ព័ត៌មានបន្ថែមអំពីការចំណាយបន្ទាន់ ឬការចំណាយដែលមិនបានព្រាងទុក សូមចូលក្នុង **workandincome.govt.nz**

សម្រាប់ព័ត៌មានបន្ថែមអំពីសេវាគ្រួសារ និងសេវាសហគមន៍ សូមចូលក្នុង **familyservices.govt.nz**